**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥១១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញា
## មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៩៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់នូវឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ(**ម.ម.ជ.**) សម្រាប់ប្រើប្រាស់បំពេញការងារនៅ**ម.ម.ជ.** និងចុះអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជានិងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យមាត្រាសាស្ត្រទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ឯកសណ្ឋាន សញ្ញាសក្តិ និងមួក

### ផ្នែកទី១

### ឯកសណ្ឋាន

**មាត្រា២ .-**

ឯកសណ្ឋានរបស់មន្ត្រី**ម.ម.ជ.** ត្រូវបានកំណត់ជា២(ពីរ)ថ្នាក់ ដូចខាងក្រោម៖

១. ថ្នាក់ដឹកនាំមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នាយកដ្ឋាន ការិយាល័យ សាខា**ម.ម.ជ.** និងមន្ត្រី

ក. ឯកសណ្ឋានបុរស

- អាវដៃខ្លីពណ៌ខៀវ កបើក ថ្នេរឌុប ប៉ូលស្មាសងខាង ដឹបចង្កេះ សម្រុងជើងអាវត្រង់ស្មើ ឆែកពីក្រោយសងខាងតាមបណ្តោយខ្លួនប្រវែង២៥ស.ម. ហើយមានហោប៉ៅចំនួនបួន ហោប៉ៅខាងលើដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរបត់ប៉ះផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ និងឡេវមានត្រារូបព្រះសង្ការពណ៌មាស
- អាវដៃវែងពណ៌ខៀវ កបើក ថ្នេរឌុប ប៉ូលស្មាសងខាង ដឹបក្លីខាងមុខពីរ ឡេវធំមានត្រារូបព្រះសង្ការពណ៌មាសពីក្រោមរហូតដល់លើ សម្រុងជើងអាវត្រង់ស្មើ ឆែកពីក្រោយសងខាងតាមបណ្តោយខ្លួនប្រវែង២៥ស.ម. ហើយមានហោប៉ៅចំនួនបួនហោប៉ៅខាងលើដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរគ្មានផ្នត់កណ្តាលមានគម្របរាងចតុកោណកែង ផ្នែកខាងក្រោយមានដឹបក្លីចំនួនពីរ និងមានឆែកចំកណ្តាលនៃអាវ។ អាវដៃវែងនេះពាក់ពីខាងក្រៅ ហើយចំពោះអាវខាងក្នុង គឺអាវសឺមីពណ៌សដៃវែង ក្រវាត់កពណ៌ក្រហម សម្រាប់ប្រើក្នុងពិធីការតែប៉ុណ្ណោះ
- ខោជើងវែងពណ៌ខ្មៅ ដេរថ្នេរបង្កប់ ចង្កេះត ដឹបក្លីខាងមុខពីរ មានហោប៉ៅចំនួនបីហោប៉ៅខាងក្រោយមួយដេរបង្កប់មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធ...ចំនួនមួយ និងហោប៉ៅចំហៀងទាំងសងខាងដេរបង្កប់តាមថ្នេរ
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ

- ខ្សែក្រវ៉ាត់ពណ៌ខ្មៅ។

ខ. ឯកសណ្ឋាននារី

- អាវម៉ូដដូចបុរស ប៉ុន្តែកអាវមានរាងកអាវរបស់ស្ត្រី
- ខោម៉ូដដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ មានពណ៌ខ្មៅ ឬសំពត់ហ៊ីបពណ៌ខ្មៅ សម្រុងក្រោមជង្គង់ ផែកក្រោយ រូតចំហៀង
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវ៉ាត់ពណ៌ខ្មៅ។

រូបគំរូនៃឯកសណ្ឋាន មានដូចក្នុងឧបសម្ព័ន្ធទី១។

២. ថ្នាក់ភ្នាក់ងារ

ក. ឯកសណ្ឋានបុរស

- អាវដៃខ្លីពណ៌ខៀវ កឧប ថ្នេរឧប ចោះឡេវចុងក ប៉ូលស្មាសងខាង ហោប៉ៅពីរដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ កាត់ស្រុងវែង ជើងត្រង់ដាក់ក្នុងខោ ហើយឡេវពីមុខនិងឡេវហោប៉ៅមានពណ៌ដូចអាវ
- អាវដៃវែងពណ៌ខៀវ កបើក ថ្នេរឧប ប៉ូលស្មាសងខាង ជីបភ្លីខាងមុខពីរ ឡេវធំមានត្រារូបព្រះសង្ការពណ៌ប្រាក់ពីក្រោមរហូតដល់លើសម្រុងជើងអាវត្រង់ស្មើ ផែកពីក្រោយសងខាងតាមបណ្តោយខ្លួនប្រវែង២៥ស.ម. ហើយមានហោប៉ៅចំនួនបួន ហោប៉ៅខាងលើដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរគ្មានផ្នត់កណ្តាលមានគម្របរាងចតុកោណកែង ផ្នែកខាងក្រោយមានជីបភ្លីចំនួនពីរ និងមានផែកចំកណ្តាលនៃអាវ។ អាវដៃវែងនេះពាក់ពីខាងក្រៅ ហើយចំពោះអាវខាងក្នុង គឺអាវសឺមីពណ៌ផ្ទៃមេឃ ដៃវែង ក្រវ៉ាត់កពណ៌ខៀវសម្រាប់ប្រើក្នុងពិធីការតែប៉ុណ្ណោះ
- ខោជើងវែងពណ៌ខ្មៅ ដេរថ្នេរបង្កប់ ចង្កេះត ជីបភ្លីខាងមុខពីរ មានហោប៉ៅបី ហោប៉ៅខាងក្រោយមួយដេរបង្កប់មានគម្របរាងស្លឹកពោធិ៍ចោះរន្ធដាក់ឡេវចំនួនមួយ និងហោប៉ៅចំហៀងទាំងសងខាងដេរបង្កប់តាមថ្នេរ
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវ៉ាត់ពណ៌ខ្មៅ។

ខ. ឯកសណ្ឋាននារី

- អាវម៉ូដដូចបុរស ប៉ុន្តែកអាវមានរាងកអាវរបស់ស្ត្រី
- ខោម៉ូដដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ មានពណ៌ខ្មៅ ឬសំពត់ហ៊ីបពណ៌ខ្មៅ សម្រុងក្រោមជង្គង់ ផែកក្រោយ រូតចំហៀង
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវ៉ាត់ពណ៌ខ្មៅ។

## ផ្នែកទី២
## សញ្ញាសក្តិ

**មាត្រា៣ .-**

សញ្ញាសក្តិស្មា ត្រូវបានកំណត់ដូចខាងក្រោម៖

- បាតក្រោមប្រវែង៦(ប្រាំមួយ)សង់ទីម៉ែត្រ
- បណ្តោយពីលើបាតក្រោមប្រវែង១៣(ដប់បី)សង់ទីម៉ែត្រ
- ទទឹងមុខកាត់ផ្នែកខាងលើប្រវែង៤,៧សង់ទីម៉ែត្រ មានរាងកោងជាមុំទាល។

សញ្ញាសក្តិស្មា មានប្រាំបីថ្នាក់ខុសៗគ្នា៖

១. ថ្នាក់ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ : មានផ្ទៃពណ៌ស ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ប៉ាក់អក្សរ"**ម.ម.ជ.**"ពណ៌មាស មានក្បាច់អង្គរពណ៌មាសទំហំធំទ្រខាងក្រោម មានសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ពណ៌មាសនៅចំកណ្តាល និងមានរូបព្រះសង្ហារពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ។ រូបគំរូនៃសញ្ញាសក្តិនេះមានដូចក្នុងឧបសម្ព័ន្ធទី២។

២. ថ្នាក់អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ : មានផ្ទៃពណ៌ស ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ប៉ាក់អក្សរ "**ម.ម.ជ.**" ពណ៌មាស មានក្បាច់អង្គរពណ៌មាសទំហំតូចទ្រខាងក្រោម មានសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ពណ៌មាសនៅចំកណ្តាល និងមានរូបព្រះសង្ហារពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៣។

៣. ថ្នាក់ប្រធាននាយកដ្ឋាន : មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្គស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំធំ នៅខាងលើក្បាច់នេះមានប៉ាក់អក្សរ "**ម.ម.ជ.**"ពណ៌មាស នៅខាងលើអក្សរមានសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិពណ៌មាសនៅចំកណ្តាល និងមានរូបព្រះសង្ហារពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ហើយមានខ្សែព្សួរវេញ៣(បី) ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៤។

៤. ថ្នាក់អនុប្រធាននាយកដ្ឋាន : មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្គស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំតូច នៅខាងលើក្បាច់នេះមានប៉ាក់អក្សរ"**ម.ម.ជ.**" ពណ៌មាស នៅខាងលើអក្សរមានសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិពណ៌មាសនៅចំកណ្តាល និងរូបព្រះសង្ហារពណ៌មាសនៅចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញហើយមានខ្សែព្សួរវេញ២(ពីរ)ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះមានដូចក្នុងឧបសម្ព័ន្ធទី៥។

៥. ថ្នាក់ប្រធានការិយាល័យ : មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្គស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំតូច នៅលើក្បាច់នេះមានប៉ាក់អក្សរ"**ម.ម.ជ.**" ពណ៌មាសនៅលើអក្សរ មានសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិពណ៌មាសនៅចំកណ្តាល និងរូបព្រះសង្ហារ

ពណ៌មាស នៅចុងនៃសញ្ញាសក្តិមានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ហើយមានខ្សែព្ធរវេញ ១(មួយ)ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៦។

៦. ថ្នាក់អនុប្រធានការិយាល័យ : មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្អស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំតូច នៅលើក្បាច់នេះមានប៉ាក់អក្សរ"ម.ម.ជ."ពណ៌ប្រាក់ នៅលើអក្សរមានសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិពណ៌ប្រាក់នៅចំកណ្តាល និងរូបព្រះសង្ខារពណ៌មាសនៅចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ហើយមានខ្សែព្ធរវេញ ១(មួយ)ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះមានដូចក្នុងឧបសម្ព័ន្ធទី៧។

៧. ថ្នាក់មន្ត្រី : មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្អស់មានចម្លាក់ក្បាច់អង្គរពណ៌ប្រាក់ទំហំតូច នៅលើក្បាច់នេះមានប៉ាក់អក្សរ"ម.ម.ជ."ពណ៌ប្រាក់ នៅលើអក្សរមានសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិពណ៌ប្រាក់នៅចំកណ្តាល និងរូបព្រះសង្ខារពណ៌មាស នៅចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌ប្រាក់ព័ទ្ធជុំវិញ ហើយមានខ្សែព្ធរវេញ១(មួយ) ខ្សែពណ៌ប្រាក់ព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៨។

៨. ថ្នាក់ភ្នាក់ងារ : មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្អស់មានចម្លាក់ក្បាច់អង្គរពណ៌ប្រាក់ទំហំតូច នៅលើក្បាច់នេះមានប៉ាក់អក្សរ"ម.ម.ជ."ពណ៌ប្រាក់ នៅលើអក្សរមានសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិពណ៌ប្រាក់នៅចំកណ្តាល និងរូបព្រះសង្ខារពណ៌ប្រាក់នៅចុងនៃសញ្ញាសក្តិមានក្បាច់ភ្ញីទេសពណ៌ប្រាក់ព័ទ្ធជុំវិញ ហើយមានខ្សែព្ធរវេញ១(មួយ)ខ្សែពណ៌ប្រាក់ព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះមានដូចក្នុងឧបសម្ព័ន្ធទី៩។

## ផ្នែកទី៣

## មួក

**មាត្រា៤ .-**

មួកកាស្កែត ត្រូវបានរៀបចំជា៦(ប្រាំមួយ)ថ្នាក់៖

១. ថ្នាក់ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ : មួកកាស្កែតធ្វើពីកំណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ខារពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង ៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ខារ មានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសដល់ជើងមួក និងខាងក្រោមក្បាច់មានប៉ាក់វណ្ណព្ធរពណ៌មាសពីលើកំណាត់ខ្សែនពណ៌ខៀវព័ទ្ធជុំវិញ ព្រមទាំងនៅខាងចុងខ្សែវណ្ណទាំងពីរខាងមានភ្ជាប់ឡេវរូបព្រះសង្ខារពណ៌មាស។ ខាងក្រោមនៃប៉ាក់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសទម្រង់ស្លែងក្របីធំដល់ជើងមួក។

២. ថ្នាក់អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ : មួកកាស្កែតធ្វើពីកំណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ខារពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង ៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ខារមានប៉ាក់វណ្ណព្ធរពណ៌មាសពីលើកំណាត់ខ្សែ

ខ្សែនពណ៌ខៀវព័ទ្ធជុំវិញ ព្រមទាំងនៅសងខាងចុងខ្សែវណ្ណទាំងពីរខាងភ្ជាប់ដោយទ្បេវរូបព្រះសង្ហារពណ៌មាស។ ខាងក្រោមនៃប៉ាក់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅនៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេស ប៉ាក់ពណ៌មាសទម្រង់ស្នែងក្របីជំដល់ជើងមួក។

៣. ថ្នាក់ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន : មួកកាស្កេតធ្វើពីកំណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ហារពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ហារមានកណ្តាប់វណ្ណពណ៌មាសនៅពីលើកំណាត់ខ្សែនពណ៌ខៀវព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងក្រោមកណ្តាប់វណ្ណដែលនៅពីលើក្បាំងមានកម្រងខ្សែសយពណ៌មាសនៅខាងចុងកម្រងខ្សែសយទាំងពីរខាងមានភ្ជាប់ទ្បេវព្រះសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសទម្រង់ស្នែងក្របីជំដល់ជើងមួក។

៤. ប្រធានការិយាល័យ អនុប្រធានការិយាល័យ : មួកកាស្កេតធ្វើពីកំណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ហារពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ហារមានកណ្តាប់វណ្ណពណ៌មាសធ្វើពីលើកំណាត់ខ្សែនពណ៌ខៀវព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងក្រោមកណ្តាប់វណ្ណដែលនៅពីលើក្បាំងមានកម្រងខ្សែសយពណ៌មាស ព្រមទាំងនៅសងខាងចុងខ្សែទាំងពីរខាងភ្ជាប់ដោយទ្បេវព្រះសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសទម្រង់ស្នែងក្របី ដោយចុងសងខាងទុកចន្លោះ៤(បួន) ស.ម. ពីជើងមួក។

៥. ថ្នាក់មន្ត្រី : មួកកាស្កេតធ្វើពីកំណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ហារពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ហារមានកណ្តាប់វណ្ណពណ៌មាសធ្វើពីលើកំណាត់ខ្សែនពណ៌ខៀវព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងក្រោមកណ្តាប់វណ្ណដែលនៅពីលើក្បាំងមានកម្រងខ្សែសយពណ៌មាស ព្រមទាំងនៅសងខាងចុងខ្សែទាំងពីរខាងភ្ជាប់ដោយទ្បេវព្រះសង្ហារពណ៌មាស។ នៅលើក្បាំងមួកគ្មានប៉ានក្បាច់ភ្ញីទេសទេ។

៦. ថ្នាក់ភ្នាក់ងារ : មួកកាស្កេតធ្វើពីកំណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ហារពណ៌ប្រាក់ទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ហារមានកណ្តាប់វណ្ណពណ៌ប្រាក់ធ្វើពីលើកំណាត់ខ្សែនពណ៌ខៀវព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងក្រោមកណ្តាប់វណ្ណដែលនៅពីលើក្បាំងមានកម្រងខ្សែសយពណ៌ប្រាក់ ព្រមទាំងនៅសងខាងចុងខ្សែទាំងពីរខាងភ្ជាប់ដោយទ្បេវព្រះសង្ហារពណ៌ប្រាក់។ នៅលើក្បាំងមួកគ្មានប៉ានក្បាច់ភ្ញីទេសទេ។ រូបគំរូនៃមួកខាងលើ មានដូចក្នុងឧបសម្ព័ន្ធទី១០។

## ជំពូកទី៣
## សញ្ញាសម្គាល់

**មាត្រា៥ .-**

សញ្ញាពាក់នៅលើដៃអាវខាងស្តាំ ជាសញ្ញាក្រសួងឧស្សាហកម្មនិងសិប្បកម្មធ្វើអំពីកំណាត់ក្រាស់រាងជារង្វង់មានអង្កត់ផ្ចិតប្រវែង៨ស.ម.។

**មាត្រា៦ .-**

សញ្ញាសម្គាល់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិមានរាងមូលប៉ោងទំហំ៤,៧ស.ម. ធ្វើអំពីស្ពាន់ភ្ជាប់ដោយបន្ទះស្បែក សម្រាប់ពាក់នៅលើហោប៉ៅអាវស្តាំដែលត្រូវកំណត់សម្គាល់ ដូចខាងក្រោម៖

- ផ្ទៃ : មានពណ៌ផ្ទៃខៀវនិងក្រហម
- កូនទម្ងន់ : មានពណ៌ស
- ផែនទី : មានពណ៌បៃតង ជាតំណាងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៧ .-**

សញ្ញាសម្រាប់ប៉ាក់ជាប់ចុងកអាវមានរូបម៉ែត្រ២(ពីរ)ខ្វែងគ្នា និងមានកូនទម្ងន់នៅពីក្រោមខ្វែងជាតំណាងស្តង់ដាគោលជាតិ។

**មាត្រា៨ .-**

ស្លាកសម្គាល់ឈ្មោះមន្ត្រី សម្រាប់ពាក់នៅពីលើហោប៉ៅអាវខាងស្តាំមានរាងចតុកោណកែងដែលមានបណ្តោយប្រវែង៩,៥ស.ម. ទទឹង២,០ស.ម. ដែលសរសេរអក្សរពណ៌ទឹកមាស និងពាសដោយជ័រឹងថ្លាមានផ្ទៃពណ៌ខ្មៅ និងមានខ្សែបន្ទាត់ស្តើងពណ៌មាសព័ទ្ធជុំវិញ ដែលមានទំហំ០,១៥ស.ម.។ ប៉ែកខាងស្តាំដៃនៃស្លាកឈ្មោះមានសញ្ញាក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងប៉ែកខាងឆ្វេងមានសរសេរគោត្តនាមនិងនាមជាអក្សរខ្មែរ អក្សរឡាតាំង និងមានអត្តលេខរបស់មន្ត្រីរាជការ។

**មាត្រា៩ .-**

ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាសម្គាល់ដូចមានចែងក្នុងមាត្រាខាងលើនេះ ត្រូវបានផ្តល់ដល់មន្ត្រីម្នាក់ៗចំនួន២(ពីរ)កំប្លេ នូវឯកសណ្ឋានខ្លីឬវែង សម្រាប់ប្រើប្រាស់ក្នុងរយៈពេល ១(មួយ)ឆ្នាំ។

**មាត្រា១០ .-**

មន្ត្រី**ម.ម.ជ.** និងមន្ត្រីសាខា**ម.ម.ជ.** ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិ មួក សញ្ញាសម្គាល់ និងត្រូវមានបណ្ណសម្គាល់ខ្លួនមន្ត្រីរាជការ លិខិតបញ្ជាបេសកកម្ម ឬលិខិតឧទ្ទេសនាមក្នុងពេលបំពេញបេសកកម្ម។ ក្នុងពិធីប្រជុំឬពិធីការផ្សេងៗទៀត បើចាំបាច់ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាសម្គាល់ ដូចមានចែងក្នុងមាត្រា២ ជំពូកទី២នៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## នៃអនុក្រឹត្យលេខ..៧១១..អនក្រ.បក ចុះថ្ងៃទី..១៩... ខែ..កក្កដា..... ឆ្នាំ២០១៤

## ស្តីពី ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

### ឯកសណ្ឋាន



## ឯកសណ្ឋាន



# ឧបសម្ព័ន្ធទី២

## នៃអនុក្រឹត្យលេខ.២១១..អនក្រ.បក.ចុះថ្ងៃទី..០៣.. ខែ.កក្កដា..... ឆ្នាំ២០១៤

## ស្តីពី ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

### សញ្ញាសក្តិសម្រាប់ប្រធាន ម.ម.ជ.



# ឧបសម្ព័ន្ធទី៣

**នៃអនុក្រឹត្យលេខ២១១.អនក្រ.បក. ចុះថ្ងៃទី.០៩.. ខែ.កក្កដា..... ឆ្នាំ២០១៤**

**ស្ដីពី ឯកសណ្ឋាន សញ្ញាសក្ដិ មួក និងសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ**

**សញ្ញាសក្ដិសម្រាប់អនុប្រធាន ម.ម.ជ.**



# ឧបសម្ព័ន្ធទី៤

## នៃអនុក្រឹត្យលេខ៤២១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១៤

## ស្តីពី ឯកសណ្ឋាន សញ្ញាសក្តិ ម្កុដ និងសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

### សញ្ញាសក្តិសម្រាប់ប្រធាននាយកដ្ឋាន



## ឧបសម្ព័ន្ធទី៥

### នៃអនុក្រឹត្យលេខ២១៧ អនក្រ.បក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៤

### ស្ដីពី ឯកសណ្ឋាន សញ្ញាសក្តិ ម្កុក និងសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

### សញ្ញាសក្តិសម្រាប់អនុប្រធាននាយកដ្ឋាន



# ឧបសម្ព័ន្ធទី៦

## នៃអនុក្រឹត្យលេខ៤២១ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១៤

## ស្តីពី ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

### សញ្ញាសក្តិសម្រាប់ប្រធានការិយាល័យ



## ឧបសម្ព័ន្ធទី៧

នៃអនុក្រឹត្យលេខ..ង.១១.អនក្រ.បក ចុះថ្ងៃទី..០៩.. ខែ..កក្កដា... ឆ្នាំ២០១៤

ស្ដីពី ឯកសណ្ឋាន សញ្ញាសក្ដិ មួក និងសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

### សញ្ញាសក្ដិសម្រាប់អនុប្រធានការិយាល័យ



# ឧបសម្ព័ន្ធទី៨

**នៃអនុក្រឹត្យលេខ...៧១១ អនក្រ.បក...ចុះថ្ងៃទី...០៩...ខែ...កក្កដា... ឆ្នាំ២០១៤**

**ស្តីពី ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ**

## សញ្ញាសក្តិសម្រាប់មន្ត្រី



**ឧបសម្ព័ន្ធទី៩**

**នៃអនុក្រឹត្យលេខ...៤៧១.អនក្រ.បក...ចុះថ្ងៃទី..០៩.. ខែ...កក្កដា... ឆ្នាំ២០១៤**

**ស្តីពី ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ**

**សញ្ញាសក្តិសម្រាប់ភ្ជាប់ខារ**



# ឧបសម្ព័ន្ធទី១០

## នៃអនុក្រឹត្យលេខ៧១១ អនក្រ.បក ចុះថ្ងៃទី...១៩... ខែ..កក្កដា... ឆ្នាំ២០១៤

## ស្តីពី ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

### មួកកាស្កេត

| | |
|---|---|
|  | មួកកាស្កេត សម្រាប់ប្រធាន ម.ម.ជ. |
|  | មួកកាស្កេត សម្រាប់អនុប្រធាន ម.ម.ជ. |
|  | មួកកាស្កេត សម្រាប់ប្រធាន អនុប្រធាននាយកដ្ឋាន |
|  | មួកកាស្កេត សម្រាប់ប្រធាន អនុប្រធានការិយាល័យ |
|  | មួកកាស្កេត មន្ត្រី |
|  | មួកកាស្កេត មន្ត្រីផ្ទាក់ងារ |